# វិទ្យាល័យ Wesley ថ្លៃឈ្នួល និងការចំណាយ ឆ្នាំ2025

WESLEY COLLEGE

MELBOURNE AUSTRALIA - SINCE 1866

## និស្សិតអន្តរជាតិ

ពាក្យសុំទាំងអស់ត្រូវបានផ្តល់អាទិភាពដោយផ្អែកលើកាលបរិច្ឆេទនៃការទទួលពាក្យសុំ ក៏ដូចជាការពិចារណាលើលក្ខណៈវិនិច្ឆ័យមួយចំនួន នៅពេលធ្វើការផ្តល់ជូនការចុះឈ្មោះចូលរៀន។ សូមមើលគេហទំព័ររបស់យើងសម្រាប់ព័ត៌មានលម្អិត អំពីរបៀបដែលយើងវាយតម្លៃពាក្យសុំរបស់យើង។

### ថ្លៃដាក់ពាក្យ

AUD$300 ត្រូវបង់ជាមួយពាក្យសុំចុះឈ្មោះ។ លើកលែងតែមានចែងក្នុងគោលការណ៍សងប្រាក់វិញ *(នីតិវិធីចុះឈ្មោះចូលរៀនវិទ្យាល័យ Wesley - អន្តរជាតិ)* ថ្លៃឈ្នួលនេះមិនអាចសងវិញ ឬក៏អាចផ្ទេរបានឡើយ។ ថ្លៃឈ្នួលនេះត្រូវបានលើកលែងសម្រាប់កូនៗ និងចៅៗពួកសិស្សចាស់នៃវិទ្យាល័យ Wesley។

### ថ្លៃឈ្នួលបញ្ជាក់ពីការចុះឈ្មោះ

AUD$1,500 ត្រូវបង់ដើម្បីបញ្ជាក់ពីការចុះឈ្មោះ។ លើកលែងតែមានចែងក្នុងគោលការណ៍សងប្រាក់វិញ *(នីតិវិធីចុះឈ្មោះចូលរៀនវិទ្យាល័យ Wesley - អន្តរជាតិ)* ថ្លៃឈ្នួលនេះមិនអាចសងវិញ ឬក៏អាចផ្ទេរបានឡើយ។

### ថ្លៃឈ្នួលប្រចាំឆ្នាំ

ថ្លៃឈ្នួលត្រូវបានបង្កើតជាសមាសភាគចាំបាច់ចំនួនបួន - ថ្លៃឈ្នួលបង្រៀន ពន្ធហេដ្ឋារចនាសម្ព័ន្ធ ពន្ធនិស្សិតអន្តរជាតិ និងថ្លៃឈ្នួលរួមបញ្ចូលគ្នា។

- ថ្លៃឈ្នួលបង្រៀន ពន្ធហេដ្ឋារចនាសម្ព័ន្ធ និងពន្ធនិស្សិតអន្តរជាតិ ត្រូវបង់ជាមុននៅថ្ងៃទី1 ខែតុលា ឆ្នាំ2024 សម្រាប់ឆមាសទី1 ឆ្នាំ2025 ហើយត្រូវបានចេញវិក្កយបត្រនៅថ្ងៃទី1 ខែមេសា ឆ្នាំ2025 សម្រាប់ឆមាសទី2 ឆ្នាំ2025។
- ថ្លៃឈ្នួលរួមបញ្ចូលគ្នាត្រូវបានចេញវិក្កយបត្រក្នុងអំឡុងឆ្នាំសិក្សា នៅថ្ងៃទី 1 ខែមេសា ឆ្នាំ2025 សម្រាប់ឆមាសទី 1 ឆ្នាំ2025 និង នៅថ្ងៃទី 1 ខែតុលា ឆ្នាំ2025 សម្រាប់ឆមាសទី 2 ឆ្នាំ2025។ សិស្សថ្នាក់ទី12 នឹងត្រូវបានចេញវិក្កយបត្រសម្រាប់ថ្លៃឈ្នួលរួមបញ្ចូលគ្នាប្រចាំឆ្នាំរបស់ពួកគេពេញ នៅថ្ងៃទី1 ខែមេសា ឆ្នាំ2025 រួមជាមួយនឹងថ្លៃឈ្នួលបង្រៀនចុងក្រោយ
- ពន្ធ GST មិនអាចអនុវត្តបានចំពោះថ្លៃឈ្នួលបង្រៀន ពន្ធហេដ្ឋារចនាសម្ព័ន្ធ ឬពន្ធនិស្សិតអន្តរជាតិទេ។ ទោះជាយ៉ាងណាក៏ដោយ ថ្លៃឈ្នួលរួមបញ្ចូលគ្នាគិតបញ្ចូលសេវាកម្មមួយចំនួនដែលពន្ធ GST អាចអនុវត្តបាន។

វិទ្យាល័យ Wesley ដំណើរការលើឆមាសចំនួនពីរ៖ អំឡុងពេលសិក្សាសរុបចំនួនពីរក្នុងមួយឆ្នាំ។

- ឆមាសទី1 រួមមានត្រីមាសទី1 និងទី2 ចាប់ពីចុងខែមករា ដល់ខែមិថុនា ដោយមានការឈប់សម្រាកវិស្សមកាលនៅខែមេសា
- ឆមាសទី2 រួមមានត្រីមាសទី3 និងទី4 ចាប់ពីខែកក្កដា ដល់ខែធ្នូ ដោយមានការឈប់សម្រាកវិស្សមកាលនៅខែកញ្ញា

ថ្លៃឈ្នួល ដូចដែលបានរៀបរាប់នៅក្នុងលិខិតផ្តល់ជូនកន្លែងរៀន គឺត្រូវបង់ពេលទទួលបានការបញ្ជាក់ពីការចុះឈ្មោះ សម្រាប់អំឡុងពេលសិក្សាពីរដំបូងនៃវគ្គសិក្សា។ បន្ទាប់ពីនោះមក ថ្លៃឈ្នួលត្រូវបង់ជាពីរដងក្នុងមួយឆ្នាំ ដោយចេញវិក្កយបត្រនៅថ្ងៃទី1 ខែមេសា និងថ្ងៃទី1 ខែតុលា។

វិទ្យាល័យមានជម្រើសបង់បណ្តាក់រយៈពេល3ខែ សម្រាប់គ្រួសារដើម្បីទូទាត់វិក្កយបត្រសម្រាប់ឆមាសថ្ងៃទី1 ខែតុលា និងថ្ងៃទី1 ខែមេសា។ សូមកត់ចំណាំ ការទូទាត់វិក្កយបត្រថ្លៃសាលានៅឆមាសទី1 ឆ្នាំ2025 គឺជាការបញ្ជាក់ពីការចុះឈ្មោះចូលរៀនឡើងវិញរបស់អ្នកជាមួយវិទ្យាល័យ Wesley និងការទទួលយកលក្ខខណ្ឌដែលបានបោះពុម្ពផ្សាយរបស់វិទ្យាល័យ ដូចដែលបានធ្វើបច្ចុប្បន្នភាពពីពេលមួយទៅពេលមួយនៅលើគេហទំព័រ។ នាយករងវិទ្យាល័យហិរញ្ញិក និងលេខាធិការវិទ្យាល័យ ត្រូវបានអនុញ្ញាតដោយក្រុមប្រឹក្សាវិទ្យាល័យ Wesley ដើម្បីចាត់វិធានការណាក៏ដោយដែលបានចាត់ទុកថាចាំបាច់ ដើម្បីទាមទារប្រាក់ដែលនៅជំពាក់។

### ថ្លៃឈ្នួលបង្រៀនប្រចាំឆ្នាំ

| កម្រិតថ្នាក់ | ថ្លៃឈ្នួលប្រចាំឆ្នាំ AUD$ |
|---|---|
| មណ្ឌលបង្រៀនកុមារតូច | 43,920 |
| ថ្នាក់ត្រៀម ទៅថ្នាក់ទី3 | 43,920 |
| ថ្នាក់ទី 4 | 44,454 |
| ថ្នាក់ទី5 និងទី6 | 46,340 |
| ថ្នាក់ទី7 និងទី8 | 49,806 |
| ថ្នាក់ទី9-12 | 53,436 |

*ថ្លៃឈ្នួលបង្រៀនប្រចាំឆ្នាំ ត្រូវបង់តាមត្រីមាសនៅពេលទទួលបានរបាយការណ៍ទូទាត់ប្រាក់*

### ពន្ធហេដ្ឋារចនាសម្ព័ន្ធ ត្រូវបង់តាមឆមាស

កុំព្យូទ័រយួរដៃមួយត្រូវបានផ្តល់ជូនសម្រាប់សិស្សថ្នាក់ត្រៀម - ថ្នាក់ទី12។

| កម្រិតថ្នាក់ | ថ្លៃឈ្នួលប្រចាំឆ្នាំ AUD$ |
|---|---|
| មណ្ឌលបង្រៀនកុមារតូច | 0 |
| ថ្នាក់ត្រៀម - ថ្នាក់ទី4 | 632 |
| ថ្នាក់ទី5 និងទី6 | 1,266 |
| ថ្នាក់ទី7-9 | 1,840 |
| ថ្នាក់ទី10-12 | 2,012 |

### ពន្ធនិស្សិតអន្តរជាតិ ត្រូវបង់តាមឆមាស*

ពន្ធនិស្សិតអន្តរជាតិចំនួន AUD5,406 អនុវត្តចំពោះនិស្សិតដែលមិនស្នាក់នៅជាអចិន្ត្រៃយ៍ទាំងអស់។

**ប្រសិនបើផ្លាស់ប្តូរស្ថានភាពស្នាក់នៅ សូមផ្តល់ភស្តុតាងទៅវិទ្យាល័យ Wesley។ ការកែតម្រូវគណនីណាមួយនឹងត្រូវបានធ្វើឡើង ចាប់ពីកាលបរិច្ឆេទផ្តល់ដំបូន្មានដល់វិទ្យាល័យ។*

### ថ្លៃឈ្នួលរួមបញ្ចូលគ្នា ត្រូវបង់តាមត្រីមាស

ការគិតថ្លៃនេះគ្របដណ្តប់លើអ្វីៗបន្ថែមដូចជាដំណើរកម្សាន្តមួយចំនួន ធនធានបណ្ណាល័យ កំណត់ហេតុប្រចាំថ្ងៃ និងសៀវភៅប្រចាំឆ្នាំរបស់វិទ្យាល័យ សៀវភៅសិក្សាមួយចំនួនសម្រាប់កុមារតូច និងសម្ភារៈសិក្សាមួយចំនួន។ វាក៏គ្របដណ្តប់លើសម្ភារៈសម្រាប់កម្មវិធីសិក្សាមន្ទីរពិសោធន៍ មជ្ឈមណ្ឌលសិក្សា និងមជ្ឈមណ្ឌលអាជីពផងដែរ។

| កម្រិតថ្នាក់ | ថ្លៃឈ្នួលប្រចាំឆ្នាំ AUD$ |
|---|---|
| មណ្ឌលបង្រៀនកុមារតូច | 956 |
| ថ្នាក់ត្រៀម ទៅថ្នាក់ទី3 | 1,132 |
| ថ្នាក់ទី4 | 1,568 |
| ថ្នាក់ទី5-12 | 2,406 |

ថ្លៃឈ្នួលនេះក៏គ្របដណ្ដប់លើការបោះជំរុំដែលធ្វើឡើងក្នុងថ្នាក់ទី4–10ផងដែរ លើកលែងតែដំណើរកម្សាន្តទៅកាន់ទីក្រុងកង់បេរ៉ា ថ្នាក់ទី6, កម្មវិធី Clunes ថ្នាក់ទី9 និងកម្មវិធីតម្រង់ទិស Yiramalay ថ្នាក់ទី10 ដែលត្រូវបានចេញវិក្កយបត្រដាច់ដោយឡែក។

សមាមាត្រនៃថ្លៃឈ្នួលដែលវិទ្យាល័យប្រមូលបាន អាចត្រូវបានប្រើដើម្បីគាំទ្រដល់ប្រតិបត្តិការរបស់ ECLC។

# ថ្លៃឈ្នួលស្នាក់នៅ

## Learning in Residence (ការស្នាក់អាស្រ័យ)

Learning in Residence ត្រូវបានផ្ដល់ជូននៅសាខា Glen Waverley តែប៉ុណ្ណោះ។ ថ្លៃឈ្នួលត្រូវបង់ជាពីរដង គឺពាក់កណ្ដាលឆ្នាំម្ដង។

| កម្រិតថ្នាក់ | ថ្លៃឈ្នួលប្រចាំឆ្នាំ AUD$ |
|---|---|
| ថ្នាក់ទី9-12 | ការស្នាក់អាស្រ័យពេញ៖ 33,500 |

## កម្មវិធី Clunes ថ្នាក់ទី9

ការចំណាយសរុបនៃកម្មវិធី Clunes ថ្នាក់ទី9គឺ AUD$5,500 សម្រាប់ត្រីមាសប្រាំបីសប្ដាហ៍ដែលសិស្សស្ថិតក្នុងកម្មវិធី Clunes។ ការចំណាយនេះគឺបន្ថែមពីលើថ្លៃឈ្នួលបង្រៀន ហើយនឹងត្រូវចេញវិក្កយបត្រមុនពេលសិស្សចូលរួមក្នុងកម្មវិធី Clunes។

## កម្មវិធីតម្រង់ទិស Yiramalay ថ្នាក់ទី10

តម្លៃសរុបសម្រាប់កម្មវិធីតម្រង់ទិស Yiramalay ថ្នាក់ទី10 រយៈពេលបីសប្ដាហ៍គឺ $ TBD ជាមួយសាលា Studio Schools Australia (មិនរាប់បញ្ចូលថ្លៃសំបុត្រយន្តហោះដែលនឹងត្រូវគិតតាមតម្លៃដើម)។ ការចំណាយនេះគឺបន្ថែមពីលើថ្លៃឈ្នួលបង្រៀន និងថ្លៃឈ្នួលរួមបញ្ចូលគ្នា ហើយនឹងត្រូវចេញវិក្កយបត្រមុនពេលសិស្សចូលរួមក្នុងកម្មវិធី Yiramalay។

## ការធានារ៉ាប់រងសុខភាព

រដ្ឋាភិបាលអូស្ត្រាលីតម្រូវឱ្យនិស្សិតអន្តរជាតិទាំងអស់ដែលកាន់ទិដ្ឋាការសិស្ស ត្រូវតែមានការធានារ៉ាប់រងសុខភាពនិស្សិតបរទេស (OSHC) សម្រាប់រយៈពេលទាំងមូលនៃទិដ្ឋាការសិស្សរបស់ពួកគេ និងការស្នាក់នៅក្នុងប្រទេសអូស្ត្រាលី។ សូមចូលទៅកាន់គេហទំព័ររបស់ក្រសួងអន្តោប្រវេសន៍ និងការពារព្រំដែន www.border.gov.au សម្រាប់ព័ត៌មានពាក់ព័ន្ធទាំងអស់។ នេះជាទំនួលខុសត្រូវរបស់អ្នកដាក់ពាក្យសុំដែលត្រូវទិញ OSHC មុនពេលចាប់ផ្ដើមដាក់ពាក្យសុំទិដ្ឋាការតាមអនឡាញ និងផ្ដល់ភស្តុតាងនៃគោលនយោបាយធានារ៉ាប់រង និងកាលបរិច្ឆេទធានារ៉ាប់រងទៅវិទ្យាល័យ Wesley មុនពេលចាប់ផ្ដើម។

## សេចក្ដីជូនដំណឹងអំពីការដកសិស្សចេញពីវិទ្យាល័យ

ការជូនដំណឹងមួយត្រីមាសជាលាយលក្ខណ៍អក្សរទៅប្រធានសាខាត្រូវបានទាមទារ ដើម្បីជូនដំណឹងអំពីការដកសិស្សចេញពីវិទ្យាល័យ បើមិនដូច្នេះទេត្រូវបង់ការគិតថ្លៃដែលស្មើនឹងថ្លៃឈ្នួលមួយត្រីមាស។ នេះមានន័យថា ការជូនដំណឹងត្រូវបានទាមទារនៅត្រឹមចុងត្រីមាសទី 3។

ការជូនដំណឹងពីរត្រីមាសត្រូវបានទាមទារ ដើម្បីជូនដំណឹងអំពីការដកសិស្សចេញពី ECLC អាយុបួនឆ្នាំ។ នេះមានន័យថា ការជូនដំណឹងត្រូវបានទាមទារនៅត្រឹមចុងត្រីមាសទី 2 បើមិនដូច្នេះទេត្រូវបង់ការគិតថ្លៃដែលស្មើនឹងថ្លៃឈ្នួលមួយត្រីមាស។

# ការបញ្ចុះតម្លៃ

## ការបញ្ចុះតម្លៃជាលក្ខណៈគ្រួសារ

នៅ Wesley ការអប់រំសិស្សប្រុសស្រីរួមគ្នា គឺជាចំណុចសំខាន់នៃចក្ខុវិស័យរបស់យើងសម្រាប់ការរៀនសូត្រ ក៏ដូចជាការប្ដេជ្ញាចិត្តរបស់យើងក្នុងការរក្សាកុមារនៅក្នុងគ្រួសារតែមួយជាមួយគ្នា។

ការបញ្ចុះតម្លៃជាលក្ខណៈគ្រួសារអនុវត្តចំពោះថ្លៃឈ្នួលបង្រៀនតែប៉ុណ្ណោះ ដែលមានកុមារបីនាក់ឡើងទៅរៀននៅវិទ្យាល័យ Wesley ហើយការបញ្ចុះតម្លៃគឺ 20% សម្រាប់កូនទីបី និង 50% សម្រាប់កូនទីបួន និងកូនបន្តបន្ទាប់ទៀត។*

** ការបញ្ចុះតម្លៃ 10% សម្រាប់កូនទីពីរក៏មានផ្ដល់ជូនផងដែរ នៅពេលដែលកូនទីបីបានចាប់ផ្ដើម ហើយការចុះឈ្មោះគឺធ្វើក្នុងពេលជាមួយគ្នា។*

ប្រសិនបើអ្នកមានសិទ្ធិទទួលបានការបញ្ចុះតម្លៃ វាត្រូវបានអនុវត្តដោយស្វ័យប្រវត្តិទៅក្នុងគណនីរបស់អ្នក។

ការបញ្ចុះតម្លៃជាលក្ខណៈគ្រួសារមិនអនុវត្តចំពោះថ្លៃឈ្នួលរួមបញ្ចូលគ្នា ពន្ធហេដ្ឋារចនាសម្ព័ន្ធ ឬថ្លៃឈ្នួល និងការគិតថ្លៃឈ្នួលឯទៀតដែលត្រូវបានចេញវិក្កយបត្រទៅក្នុងគណនីរបស់អ្នកទេ។

គ្រួសារនានាដែលបានទទួលទម្រង់ជំនួយថ្លៃឈ្នួលឯទៀត ប្រហែលជាមិនមានសិទ្ធិទទួលបានការបញ្ចុះតម្លៃជាលក្ខណៈគ្រួសារទេ។

## ការបញ្ចុះតម្លៃលើការទូទាត់ប្រាក់បានមុនពេល

ការបញ្ចុះតម្លៃ 2.5% អាចមានផ្ដល់ជូន ប្រសិនបើថ្លៃឈ្នួលប្រចាំឆ្នាំសរុបត្រូវបានបង់ជាមុន ឧទាហរណ៍ ឆ្នាំ2025 បង់ត្រឹមថ្ងៃទី31 ខែតុលា ឆ្នាំ2024។

ការបញ្ចុះតម្លៃនេះអនុវត្តចំពោះថ្លៃឈ្នួលបង្រៀន និងថ្លៃឈ្នួលរួមបញ្ចូលគ្នាតែប៉ុណ្ណោះ។

# ការចំណាយ

## ការប៉ាន់ស្មានការចំណាយលើការរស់នៅប្រចាំសប្ដាហ៍

នេះត្រូវបានគេប៉ាន់ស្មានថា សិស្សម្នាក់ៗនឹងត្រូវការប្រាក់ប្រហែលជា AUD$100–AUD$150 ក្នុងមួយ សប្ដាហ៍ដើម្បីគ្របដណ្ដប់លើការចំណាយដូចខាងក្រោម៖

- ការដឹកជញ្ជូន
- ទូរសព្ទចល័ត
- កន្លែងស្នាក់នៅ
- វេជ្ជសាស្ត្រ
- ការចំណាយសម្រាប់របស់របរផ្សេងៗដូចជាកាត់សក់ សំលៀកបំពាក់ ការកម្សាន្ត ការញ៉ាំអាហារក្រៅផ្ទះជាដើម។

## ការចំណាយឯទៀត

ការចំណាយបន្ថែមទៀតនឹងកើតមានឡើងសម្រាប់ការទិញឯកសណ្ឋានសាលា (ដែលមានតម្លៃចាប់ពី AUD$1,000 – AUD$1,500) សៀវភៅ និងសម្ភារៈសិក្សា (ប្រហែលជា AUD$500) និងឧបករណ៍កីឡាណាមួយដែលតម្រូវ។

# សេចក្ដីសង្ខេបនៃការចំណាយលើការចុះឈ្មោះ

| ការគិតថ្លៃ | ថ្លៃឈ្នួលប្រចាំឆ្នាំ AUD$ |
|---|---|
| ថ្លៃដាក់ពាក្យសុំ* | 300 |
| ថ្លៃឈ្នួលបញ្ជាក់ពីការចុះឈ្មោះ* | 1,500 |
| ថ្លៃឈ្នួលបង្រៀន (ថ្នាក់ទី9–12) | 53,436 |
| ពន្ធហេដ្ឋារចនាសម្ព័ន្ធ (ថ្នាក់9–12) | 2,012 |
| ថ្លៃឈ្នួលរួមបញ្ចូលគ្នា (ថ្នាក់ទី5-12) | 2,406 |
| ពន្ធនិស្សិតអន្តរជាតិ | 5,406 |
| **ការចំណាយសរុប** | **65,060** |

** ថ្លៃឈ្នួលទាំងនេះត្រូវបង់អំឡុងពេលដាក់ពាក្យសុំ និងដំណើរការចុះឈ្មោះ ហើយមិនមែនជាថ្លៃឈ្នួលប្រចាំឆ្នាំទេ។*

## ការធានារ៉ាប់រងគ្រោះថ្នាក់សិស្ស

វិទ្យាល័យ Wesley មានមោទនភាពចំពោះកម្រិតនៃការថែទាំ និងការផ្តល់បរិយាកាសសិក្សាប្រកបដោយសុវត្ថិភាពសម្រាប់សិស្សទាំងអស់។

សូម្បីតែនៅក្នុងបរិយាកាសដែលមានសុវត្ថិភាពបំផុតក៏ដោយ គ្រោះថ្នាក់ និងការរងរបួសនៅតែអាចកើតមានឡើង។ ក្រុមប្រឹក្សាវិទ្យាល័យ ដោយទទួលស្គាល់ថាអាចមានការចំណាយពាក់ព័ន្ធនឹងការរងរបួសរបស់សិស្ស បានទិញ *"គោលនយោបាយធានារ៉ាប់រងគ្រោះថ្នាក់សិស្សជាក្រុម"* ដែលត្រូវបានផ្តល់ជូនដោយឥតគិតថ្លៃដល់គ្រួសារទាំងអស់។

## វិធីសាស្ត្រនៃការទូទាត់ប្រាក់

ថ្លៃឈ្នួល និងការគិតថ្លៃអាចបង់បានដោយ៖

- មូលប្បទានប័ត្រ
- កាតឥណទាន - MasterCard និង Visa (គិតថ្លៃឈ្នួលបន្ថែម)
- ការគិតថ្លៃកាត - American Express (គិតថ្លៃឈ្នួលបន្ថែម)
- BPAY (គិតថ្លៃឈ្នួលបន្ថែម) ឬ
- ការផ្ទេរឥណទានផ្ទាល់ (ទៅ៖

  ធនាគារ៖ NAB
  ឈ្មោះគណនី៖ វិទ្យាល័យ Wesley ទីក្រុងមែលប៊ន
  លេខកូដសាខា (BSB)៖ 083 004
  330 Collins Street Melbourne
  លេខគណនី៖ 117480554
  លេខកូដ Swift៖ NATAAU3303M

## ព័ត៌មានបន្ថែម

សូមចំណាំថាថ្លៃឈ្នួលប្រចាំឆមាសទី 1 ក្នុងឆ្នាំ 2025 ឆ្លុះបញ្ចាំងពីពន្ធលើប្រាក់បៀវត្សរ៍របស់រដ្ឋាភិបាលរដ្ឋវិចថូរៀ ចាប់ពីថ្ងៃទី1 ខែកក្កដា ឆ្នាំ2024។

សូមកត់ចំណាំថាថ្លៃឈ្នួលត្រូវបានពិនិត្យជារៀងរាល់ឆ្នាំ ហើយអាចផ្លាស់ប្តូរបាន តាមការសម្រេចចិត្តរបស់វិទ្យាល័យ។



Elsternwick 5 Gladstone Parade Elsternwick Victoria 3185 elsternwick@wesleycollege.net
Glen Waverley 620 High Street Road Glen Waverley Victoria 3150 gw@wesleycollege.net
St Kilda Road 577 St Kilda Road Melbourne Victoria 3004 stkildaroad@wesleycollege.net
ទូរស័ព្ទ៖ + 61 3 8102 6888
www.wesleycollege.edu.au
ABN 55 611 238 530 CRICOS 00354G